សេចក្តីស្នើរសុំរបស់ តារាវិចិត្រ តំណាងសមាគមចលនាស្ត្រីខ្មែរ នៅប្រទេសបារាំង
ពីពាក្យមិនពិរោះទៅលើ កញ្ញា កឹម មនោវិទ្យា

សូមជំរាបសួរ និងគោរពបងប្អូនខ្មែរទាំងអស់,

ជាដំបូងសូមមេត្តាអភ័យទោសជាមុន ប្រសិនបើមានពាក្យមិនសមរម្យ។ ក្នុងនាមជាស្រី ពិបាកនឹងទទួលនូវពាក្យអាស្រូវពីបុរសណាស់។ កញ្ញា កឹម មនោវិទ្យា ក៏ជាស្ត្រីគំរូមួយរូប ដែលចេះបំរើការពារប្រទេសជាតិ និងជាកូនស្រីរបស់ លោកប្រធានកឹម សុខា។ រាល់ឪពុកតែងតែស្រឡាញ់កូនលើសពីជីវិតរបស់ខ្លួនទៅទៀត ស្រឡាញ់ជាតិមែនពិតតែឱបមិនបានទេ តែបើកូនវិញអាចឱបដាក់លើដើមទ្រូងបានតាមការពារកូន និងរក្សាទុកកិត្តិយសដល់គ្រួសារជានិច្ច កុំឲ្យពាក្យចាស់លោកថា «បើការពារកូនមិនបាន ទៅការពារសង្គមយ៉ាងដូចម្តេចទៅ»។

លោកកឹម សុខា ជាវីរបុរស និងជាប្រធានគណបក្សសង្គ្រោះជាតិ ដែលសមាជិកទាំងមូល ទាំងអស់ទុកចិត្តទៅលើលោក សូម្បីតែលោកប្រធានសម រង្ស៊ីគ្រប់កាលៈទេសៈ លោកតែងតែបញ្ចេញឈ្មោះលោកប្រធានកឹម សុខា ជានិច្ចរាល់ពេលដែលលោកលើកឡើងពីគណបក្សសង្គ្រោះជាតិ ព្រមទាំងបញ្ជាក់យ៉ាងច្បាស់ថា លោកកឹម សុខាជាអ្នកស្ថាបនិក គណបក្សសង្គ្រោះជាតិជាមួយនឹងលោក ។

គ្រោះថ្នាក់ដ៏ធ្ងន់ទៅទៀតគួរឲ្យព្រឺក្បាលនោះ យើងដឹងទាំងអស់គ្នា ពេលណាមានជម្លោះសត្រូវរត់ទៅអែបអប ឈ្លាតឱកាស និងទន្ទឹងរង់ចាំបំបែកបំបាក់គ្រប់ដង្ហើម នេះគ្រាន់តែជាការព្រួយបារម្ភទេ។

បងប្អូនជាទីគោរព និងជាទីរាប់អាន យើងតស៊ូរាប់ឆ្នាំមកហើយ ពេលនេះយើងមាន សង្ឃឹម សង្ឃឹមច្រើន ច្រើនមែនទែន បើបណ្តោយទៅតាមសន្ទុះបេះដូងយើង យើងនឹងរត់ទៅប្រាប់បងប្អូនខ្មែរនៅក្នុងស្រុកភ្លាមថា យើងមានសង្ឃឹមហើយបងប្អូន បន្ទាប់ពីមានការជួបជុំ គ្នានៅសហរដ្ឋអាមេរិក។

តែគ្រោះមហន្តរាយ នៅពេលដែលយើងកំពុងតែដើរលឿនទៅមុខ ដោយជោគជ័យ សត្រូវដែលអែបអបនាំបំបះបំបោរ បំបែកបំបាក់យកពាក្យដែលយើងនិយាយទៅកាន់នាង កញ្ញា កឹម មនោវិទ្យា ជាធំ។

សូមកុំភ្លេចឲ្យសោះពីប្រវត្តិសាស្ត្រខ្មែរពីការបាត់បង់ទឹកដី ដោយមានគំនុំគុំគួន ខ្មែរខ្លះទៅពឹងយួន ខ្មែរខ្លះទៅពឹងសៀម។ សូមឈប់ទៅ បងប្អូនជាទីគោរព និងជាទីរាប់អាន មេត្តាឈប់សរសេរតទៀតទៅ។

ដោយគោរព និងសុំទោសពីការផ្តាំផ្តង
តារាវិចិត្រ សមាគមចលនាស្ត្រីខ្មែរ ប្រទេសបារាំង